## ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
## អភិបូជានៅព្រះសហគមន៍ត្រែងត្រយឹង
## ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៨

*ព្រះរាជ្យរបស់ព្រះជាម្ចាស់នៅឯណា?*

អត្ថបទទី១៖ យណ ៣,១-៥.១០
អត្ថបទទីពីរ៖ ១ករ ៧,២៩-៣១
ដំណឹងល្អ៖ មក ១,១៤-២០

បងប្អូនជាទីស្រឡាញ់!

យើងបានចេញពីបុណ្យព្រះយេស៊ូប្រសូត ក្រោយមកព្រះយេស៊ូបានសម្តែងឋានៈព្រះអង្គឲ្យមនុស្សលោកឃើញ ក្រោយមកព្រះយេស៊ូបានទទួលពិធីជ្រមុជទឹក។ នៅក្នុងជីវិតរបស់ព្រះយេស៊ូ យើងស្គាល់ព្រះយេស៊ូនៅពេលប្រសូត នៅពេលព្រះយេស៊ូបង្ហាញខ្លួន នៅព្រះយេស៊ូគេចខ្លួនជាមួយឪពុកម្តាយទៅប្រទេសអេហ្ស៊ីប និងនៅពេលព្រះយេស៊ូត្រលប់មកវិញនៅភូមិណាសារ៉ែត។ ព្រះយេស៊ូរីកចម្រើនបន្តិចម្តងៗ នៅអាយុ១២ឆ្នាំព្រះអង្គបានទៅដល់ព្រះវិហារទីក្រុងយេរូសាឡឹម ជាមួយឪពុកម្តាយដើម្បីគោរពប្រពៃណី ក្រោយមកយើងមិនដឹងអំពីព្រះយេស៊ូរហូតដល់ថ្ងៃនេះ ព្រះយេសស៊ូទទួលពិធីជ្រមុជទឹក ហើយព្រះយេស៊ូចេញពីភូមិណាសារ៉ែត ពេលអាយុ៣០ឆ្នាំព្រះបន្ទូលដំបូងរបស់ព្រះយេស៊ូគឺ **ពេលកំណត់មកដល់ហើយ រីឯព្រះរាជ្យរបស់ព្រះជាម្ចាស់ក៏មកជិតបង្កើយដែរ ចូរនាំគ្នាប្រែចិត្តគំនិតហើយជឿដំណឹងល្អចុះ។** នៅក្នុងព្រះបន្ទូលនេះ មានគម្រោងការរបស់ព្រហជាម្ចាស់សម្រាប់យើងទាំងអស់គ្នា ទីមួយ ព្រះជាម្ចាស់យាងមកដើម្បីឲ្យយើងរួមរស់នៅក្នុងព្រះរាជ្យរបស់ព្រះអង្គ។ **ព្រះរាជ្យរបស់ព្រះជាម្ចាស់នៅឯណា?** ដើម្បីទៅដល់ស្ថាបរមសុខគឺត្រូវចាប់ផ្តើមនៅទីនេះ ដោយសារព្រះយេស៊ូមានព្រះបន្ទូលថា ព្រះរាជ្យរបស់ព្រះជាម្ចាស់មកជិតបង្កើយដែរ មានន័យថាយើងជិតមើលឃើញ។ បើយើងស្តាប់ធម្មទេសនាដំបូងរបស់ព្រះយេស៊ូ ព្រះអង្គបាននិយាយថា **"នៅថ្ងៃនេះព្រះបន្ទូលរបស់ព្រះជាម្ចាស់បានកើតជារូបរាងហើយ"** នៅពេលយើងមើលព្រះយេស៊ូ យើងមើលព្រះរាជ្យរបស់ព្រះជាម្ចាស់។ ហេតុនេះហើយ ព្រះរាជ្យរបស់ព្រះជាម្ចាស់មិនមែនទីក្រុងមួយឬកន្លែងមួយនៅលើផែនដីនេះ ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺនៅកន្លែងដែលព្រះយេស៊ូគង់នៅ។ ព្រះយេស៊ូមានព្រះបន្ទូលថា **"នៅពេលយើងមានពីរបីនាក់ដែលជួបជុំគ្នាដោយនាមខ្ញុំ នៅពេលនោះខ្ញុំគង់នៅជាមួយបងប្អូន"** ហេតុនេះហើយថ្ងៃនេះយើងដឹងថាព្រះយេស៊ូគង់នៅជាមួយយើង។ ថ្ងៃនេះ យើងមើលឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលកំពុងយាងមក បងប្អូនទាំងអស់ជាសញ្ញា

សម្គាល់នៃជីវិតរបស់ព្រះយេស៊ូ បងប្អូនទាំងអស់ជាសញ្ញាសម្គាល់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ ពេលបងប្អូនអង្គុយដោយនាមព្រះយេស៊ូ រួមជាមួយលោកបូជាចារ្យដែលជាគ្រូគង្វាល យើងដឹងថាព្រះយេស៊ូគង់នៅជាមួយយើង យើងដឹងថាព្រះរាជ្យរបស់ព្រះជាម្ចាស់កំពុងមានដំណើរការនៅទីនេះ។ ពេលព្រះយេស៊ូឡើងលើភ្នំ **ទីមួយព្រះយេស៊ូអធិដ្ឋាន ទីពីរព្រះយេស៊ូប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ទីបីព្រះយេស៊ូអនុវត្ត** ដោយឲ្យនំប៉័ងដល់អ្នកក្រីក្រ ដោយឲ្យអ្នកជំងឺជាសះស្បើយ។ ព្រះរាជ្យរបស់ព្រះជាម្ចាស់ យើងមើលឃើញនៅពេលយើងជាគ្រីស្តបរិស័ទ ទីមួយជួបជុំគ្នាដើម្បីអធិដ្ឋាន ទីពីរយកចិត្តទុកដាក់ជាមួយបងប្អូនឯទៀតៗ។ ឲ្យយើងចេះស្រឡាញ់ក្រុមគ្រួសារយើង ដោយចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ឲ្យព្រះសហគមន៍របស់យើងមានជីវិត ដោយយកចិត្តទុកដាក់ចូលអភិបូជា អធិដ្ឋាន។ យើងធ្វើដូចម្ដេច ដើម្បីឲ្យកន្លែងរបស់យើងទៅជាកន្លែងមួយដែលយើងចេះស្រឡាញ់គ្នាទៅវិញទៅមកដូចបងប្អូនបង្កើត។ សញ្ញាសម្គាល់ពិសេស ដែលយើងអាចបង្ហាញដល់បងប្អូនឯទៀតៗ ជាពិសេសអ្នកជិតខាងឲ្យគេយល់ថាគ្រីស្តបរិស័ទនៅទីនេះគេជួបជុំគ្នា ស្រឡាញ់គ្នា លើកលែងទោសឲ្យគ្នា ចេះជួយគ្នា ជាក្រុមដែលចេះស្រឡាញ់គ្នាដូចបងប្អូនបង្កើត។ នេះណែនាំឲ្យអ្នកដទៃឆ្ងល់ និងយល់អំពីជីវិតជាគ្រីស្តបរិស័ទ ណែនាំឲ្យយើងយល់ថាព្រះរាជ្យរបស់ព្រះជាម្ចាស់គឺពេលយើងជួបជុំគ្នាសប្បាយជាមួយគ្នា គោរពគ្នា ជួយគ្នា លើកទឹកចិត្តគ្នា។ ដើម្បីឲ្យព្រះរាជ្យរបស់ព្រះជាម្ចាស់ទៅដល់ យើងត្រូវការចេញពីកន្លែងយើង ដូចព្រះយេស៊ូបានចេញពីភូមិណាសារ៉ែត ដើម្បីដើរពីភូមិមួយទៅភូមិមួយ ដើម្បីឲ្យគេឃើញសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។ យើងជាគ្រីស្តបរិស័ទ យើងចេញពីព្រះសហគមន៍របស់យើងដើម្បីប្រកាសដំណឹងល្អ។ ជីវិតរបស់យើងជាគ្រីស្តបរិស័ទមិនមែនតែពេលយើងចូលព្រះវិហារតែប៉ុណ្ណឹង ពេលយើងទៅសាលាពេលយើងទៅធ្វើការ ពេលយើងទៅរកស៊ី យើងជាគ្រីស្តបរិស័ទដែលជាឱកាសមួយដើម្បីបង្ហាញស្នាមញញឹម ការលើកទឹកចិត្ត សេចក្ដីស្រឡាញ់ នេះជារបៀបដែលយើងបង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់ដែរ។ នៅពេលយើងចេញពីកន្លែងយើង យើងត្រូវការយល់ថាជំនឿរបស់បងប្អូនភ្ជាប់នៅក្នុងដួងចិត្ត ដោយសារយើងមានសេចក្ដីស្រឡាញ់ពីព្រះយេស៊ូ។ ដូច្នេះទីមួយជួបជុំគ្នានៅក្នុងព្រះសហគមន៍ ទីពីរយើងចេញ និងទីបីចូរកែប្រែចិត្តគំនិតយើងមិនទាន់ជាមនុស្សអស្ចារ្យ តែយើងជាមនុស្សមានបាបដែលត្រូវកែប្រែចិត្តគំនិត។ សន្តីតេរេសា គាត់បានចូលនៅក្នុងអារាសម្ញាត់គឺគាត់នៅក្មេងណាស់ ប៉ុន្តែប៉ុន្មានឆ្នាំដែលគាត់

ត្រៀមខ្លួននៅជាមួយព្រះយេស៊ូ គាត់បានទទួលស្គាល់អំពីអំពើបាបរបស់គាត់រហូតហើយចង់កែប្រែចិត្តគំនិតថែមទៀត។ គាត់មានគំនិតថា យើងជាគ្រីស្តបរិស័ទដើម្បីភ្ជាប់ជាមួយព្រះយេស៊ូយើងត្រូវការកែប្រែចិត្តគំនិត យើងមិនកែប្រែចិត្តគំនិតតែក្នុងរដូវ៤០ថ្ងៃ គឺយើងត្រូវការកែប្រែចិត្តគំនិតរាល់ថ្ងៃ។ ព្រឹកឡើងយើងត្រូវគិតថ្ងៃនេះជាថ្ងៃថ្មី យើងត្រូវយកចិត្តទុកដាក់ធ្វើជាមនុស្សល្អជាងម្សិលមិញ។ ពេលយើងកែប្រែចិត្តគំនិត យើងដឹងថាព្រះជាម្ចាស់ស្រឡាញ់យើង **ព្រះជាម្ចាស់មិនស្រឡាញ់អំពើបាប ប៉ុន្តែព្រះជាម្ចាស់ស្រឡាញ់មនុស្សបាបដែលយកចិត្តទុកដាក់កែប្រែចិត្តគំនិត**។ យើងមិនមែនជាមនុស្សដ៏វិសុទ្ធ ប៉ុន្តែបន្តិចម្តងៗយើងធ្វើដូចម្តេចដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់ ដោយថាថ្ងៃនេះខ្ញុំធ្វើដូចម្តេចដើម្បីធ្វើជាមនុស្សល្អបំផុតតាមរបៀបព្រះយេស៊ូបង្រៀនយើង។ ដើម្បីស្គាល់របៀបដែលព្រះយេស៊ូបង្រៀនយើង យើងត្រូវតែចូលអភិបូជា អធិដ្ឋាន ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ ដើម្បីស្គាល់ព្រះយេស៊ូថែមទៀត។ ថ្ងៃនេះព្រះបន្ទូលនិយាយថា ឲ្យយើងកែប្រែចិត្តគំនិតជឿលើដំណឹងល្អទៅ និងស្តាប់ព្រះបន្ទូលដោយស្តាប់ព្រះយេស៊ូកំពុងត្រាស់ហៅយើង ឲ្យយើងធ្វើដំណើរជាមួយព្រះអង្គ។

តាមរយៈព្រះនាងម៉ារី សូមព្រះអង្គជួយយើងដើម្បីឲ្យយើងបង្កើតព្រះរាជ្យរបស់ព្រះជាម្ចាស់ នៅក្នុងព្រះសហគមន៍យើង នៅខាងក្រៅព្រះសហគមន៍យើង ដោយយកចិត្តទុកដាក់កែប្រែចិត្តគំនិតជានិច្ច។ អាម៉ែន៕